# ឯកសារព័ត៌មានស្តីពីការក្ស័យធន

ច្បាប់ស្តីពីការក្ស័យធន គឺជាច្បាប់សហព័ន្ធមួយ។ ឯកសារនេះផ្តល់លោកអ្នកឲ្យបានជ្រាបអំពីព័ត៌មានទូទៅស្តីពីអ្វីដែលកើតមានឡើងនៅក្នុងករណីក្ស័យធនមួយ។ ព័ត៌មាននៅក្នុងនេះ មិនមានលក្ខណៈពេញលេញទេ។ លោកអ្នក អាចនឹងត្រូវការចាំបាច់នូវដំបូន្មានផ្នែកច្បាប់។

**<u>នៅពេលលោកអ្នកដាក់ពាក្យសម្រាប់បញ្ហាក្ស័យធន</u>**

លោកអ្នក អាចជ្រើសរើសប្រភេទនៃការក្ស័យធនដែលសមស្របបំផុតទៅនឹងតម្រូវការលោកអ្នក (លុះត្រាតែលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពិតប្រាកដ)៖

> ជំពូកទី 7 – អ្នកទទួលភារៈគ្រប់គ្រង ឬ តំណាងម្ចាស់ ត្រូវបានចាត់ឲ្យកាន់កាប់លើទ្រព្យសម្បត្តិលោកអ្នក។ ទ្រព្យសម្បត្តិមានតម្លៃណាមួយនោះ នឹងត្រូវបានលក់ ឬប្តូរជាប្រាក់ដើម្បីទូទាត់ឲ្យម្ចាស់បំណុលនានា។ លោកអ្នក អាចនឹងមានលទ្ធភាពរក្សារបស់ផ្ទាល់ខ្លួនមួយចំនួន និង អាចជាអចលនៈទ្រព្យ អាស្រ័យលើច្បាប់រដ្ឋនៅកន្លែងដែលលោកអ្នករស់នៅ ហើយនិងច្បាប់សហព័ន្ធជាធរមាន។
>
> ជំពូកទី 13 – លោកអ្នក តាមធម្មតាអាចរក្សាទុកនូវទ្រព្យសម្បត្តិរបស់លោកអ្នកបាន ប៉ុន្តែលោកអ្នកត្រូវតែរកប្រាក់កម្រៃ ឬ មានប្រភពប្រាក់ចំណូលទៀងទាត់ផ្សេងៗទៀត ហើយលោកអ្នកត្រូវតែយល់ព្រមទូទាត់ចំណែកប្រាក់ចំណូលលោកអ្នកទៅឲ្យម្ចាស់បំណុល។ តុលាការ ត្រូវតែយល់ព្រមលើការគ្រោងទូទាត់ និង គម្រោងថវិការបស់លោកអ្នក។ អ្នកតំណាងម្ចាស់ត្រូវបានចាត់ឲ្យមានឡើង ហើយនឹងត្រូវទទួលការទូទាត់សងពីលោកអ្នក ទូទាត់ឲ្យទៅម្ចាស់បំណុល ហើយនិងធ្វើឲ្យប្រាកដប្រជាថាលោកអ្នក រស់នៅបានរហូតចប់រយៈពេលនៃការគ្រោងទូទាត់សងរបស់លោកអ្នក។
>
> ជំពូកទី 12 – ដូចគ្នានឹងជំពូកទី 13 ដែរ ប៉ុន្តែវាគ្រាន់តែសម្រាប់ក្រុមគ្រួសារប្រជាកសិករ និង នេសាទប៉ុណ្ណោះ។
>
> ជំពូកទី 11 – ជំពូកនេះ ត្រូវបានប្រើប្រាស់ភាគច្រើនដោយក្រុមហ៊ុននានា។ ក្នុងជំពូកទី 11 លោកអ្នកអាចនឹងបន្តធ្វើប្រតិបត្តិការលើមុខជំនួញរបស់លោកអ្នកបាន ប៉ុន្តែម្ចាស់បំណុលរបស់លោកអ្នក និង តុលាការត្រូវតែយល់ព្រមលើការគ្រោងមួយដើម្បីទូទាត់សងបំណុលរបស់លោកអ្នក។ មិនមានអ្នកតំណាងណាម្នាក់ទេ ប្រសិនបើចៅក្រមមិនសម្រេចថាករណីនេះមិនមានលក្ខណៈចាំបាច់ ប្រសិនបើអ្នកតំណាងត្រូវបានចាត់ឲ្យមានឡើង អ្នកតំណាងនោះនឹងគ្រប់គ្រងលើមុខជំនួញ និង ទ្រព្យសម្បត្តិលោកអ្នក។

ប្រសិនបើលោកអ្នក បានដាក់ពាក្យក្ស័យធនក្រោមជំពូកទី 7 រួមហើយ លោកអ្នកអាចមានលទ្ធភាពផ្លាស់ប្តូរករណីលោកអ្នកទៅជំពូកមួយផ្សេងទៀតបាន។

បញ្ហាក្ស័យធនរបស់លោកអ្នក អាចត្រូវបានរាយការណ៍ប្រាប់លើមូលដ្ឋានកំណត់ហេតុបំណុលលោកអ្នកសម្រាប់រយៈពេលរហូតដល់ដប់ឆ្នាំ។ វាអាចមានផលប៉ះពាល់ដល់លទ្ធភាពរបស់លោកអ្នកដើម្បីទទួលបានឥណទាននៅពេលអនាគត។

**<u>តើអ្វីទៅជាការរំលត់បំណុលក្នុងការក្ស័យធន (Bankruptcy discharge) ហើយតើវាប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?</u>**

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលប្រជាពលរដ្ឋត្រូវដាក់ពាក្យក្ស័យធននោះ គឺដើម្បីទទួលបាននូវ 'ការរំលត់" មួយ។ ការរំលត់ គឺជាបញ្ជារបស់តុលាការដែលលើកឡើងថា លោកអ្នកមិនត្រូវទូទាត់បំណុលភាគច្រើនរបស់លោកអ្នកនោះទេ។ បំណុលមួយចំនួន មិនអាចរំលត់ចោលនោះទេ។ ឧទាហរណ៍៖ លោកអ្នក មិនអាចរំលត់បំណុលបានចំពោះ៖

- ពន្ធអាករភាគច្រើនបំផុត
- ជំនួយឧបត្ថម្ភសម្រាប់កូន
- សោធន(អាហារកិច្ច)
- កម្ចីភាគច្រើនសម្រាប់សិស្ស
- ប្រាក់ពិន័យរបស់តុលាការ និង ការសងវិញ ឬ បដិទានចំពោះបញ្ហាបទឧក្រិដ្ឋ និង
- របួសស្នាមផ្ទាល់ខ្លួនដែលបណ្តាលមកពីការបើកបរដោយស្រវឹងស្រា ឬ ថ្នាំញៀនស្រវឹង។

ការរំលត់នេះ គឺគ្រាន់តែអនុវត្តចំពោះបំណុលនានាដែលលេចចេញមកនៅមុនពេលកាលបរិច្ឆេទដែលលោកអ្នកបានដាក់ពាក្យតែប៉ុណ្ណោះ។ លើសពីនេះ ប្រសិនចៅក្រមរកឃើញថា លោកអ្នកបានទទួលប្រាក់ ឬ ទ្រព្យសម្បត្តិតាមរយៈការក្លែងបន្លំ បំណុលអាចនឹងមិនទទួលបានការរំលត់នោះទេ។

សំខាន់ត្រូវចុះបញ្ជីលើរាល់ទ្រព្យសម្បត្តិ និង បំណុលរបស់លោកអ្នកនៅក្នុងកំណត់កាលវិភាគក្ស័យធនរបស់លោកអ្នក។ ឧទាហរណ៍ ក្នុងករណីដែលលោកអ្នកមិនចុះបញ្ជីនូវបំណុលមួយ វាអាចមានលទ្ធភាពដែលថា បំណុលនឹងមិនទទួលបានការរំលត់។ លើសពីនេះដែរ ចៅក្រមអាចបដិសេធបានផងដែរចំពោះការរំលត់ការក្ស័យធនរបស់លោកអ្នក ប្រសិនបើលោកអ្នកធ្វើរឿងអ្វីមួយដែលមិនស្មោះត្រង់ពាក់ព័ន្ធនឹងករណីក្ស័យធនរបស់លោកអ្នក ដែលមានដូចជាបំផ្លិចបំផ្លាញ ឬ លាក់លៀមទ្រព្យសម្បត្តិ បន្លំកំណត់ហេតុ ឬ ភូតកុហក ឬ ក្នុងករណីលោកអ្នកមិនអនុវត្តតាមបញ្ជាតុលាការ។

លោកអ្នក គ្រាន់តែអាចទទួលបានការរំលត់នេះតែម្តងស្របតាមជំពូកទី 7 ប៉ុណ្ណោះ នៅរៀងរាល់ប្រាំបីឆ្នាំម្តង។ វិធានច្បាប់ផ្សេងៗទៀត អាចនឹងអនុវត្តទៅបាន ប្រសិនបើលោកអ្នកទទួលបានពីមុនមកនូវការរំលត់ការក្ស័យធនមួយស្របតាមករណីនៃជំពូកទី 13។ គ្មានអ្នកម្នាក់ អាចបង្ខំលោកអ្នកឲ្យសងបំណុលមួយដែលទទួលបានការរំលត់ហើយនោះទេ ប៉ុន្តែលោកអ្នកអាចសងដោយស្ម័គ្រចិត្តចំពោះបំណុលណាមួយដែលលោកអ្នកមានបំណងចង់សង។ លោកអ្នក មិនត្រូវចុះហត្ថលេខាលើកិច្ចសន្យាបញ្ជាក់ឡើងវិញនោះទេ (សូមមើលខាងក្រោមនេះ) ឬ លើប្រភេទឯកសារណាផ្សេងទៀតដើម្បីធ្វើដូច្នេះឡើយ។

ម្ចាស់បំណុលមួយចំនួន ធ្វើការប្តឹងទាមទារដែលមានការធានា (ឧទាហរណ៍ ធនាគារដែលធ្វើអ៊ីប៉ូតែកលើបញ្ជាផ្ទះ ឬ ក្រុមហ៊ុនប្រាក់កម្ចីដែលមានការឃាត់ទុកចំពោះរថយន្តលោកអ្នក)។ លោកអ្នក មិនត្រូវទូទាត់សងលើការប្តឹងទាមទារដែលមានការធានាមួយនោះទេ ប្រសិនបើបំណុលមានការរំលត់ហើយនោះ ប៉ុន្តែម្ចាស់បំណុលអាចនៅតែរឹបអូសយកទ្រព្យសម្បត្តិដដែល។

**<u>តើអ្វីទៅជាកិច្ចសន្យាបញ្ជាក់ឡើងវិញ?</u>**

បើទោះជាបំណុលមួយ អាចត្រូវបានរំលត់ក៏ដោយ ក៏លោកអ្នកអាចនឹងមានហេតុផលពិសេសៗដែលលោកអ្នកចង់សន្យាទូទាត់សងវា។ ឧទាហរណ៍: លោកអ្នក អាចចង់ធ្វើការដោះស្រាយឲ្យចេញនូវការគ្រោងទូទាត់សងមួយជាមួយនឹងធនាគារ ប្រយោជន៍បន្តរក្សាទុកនូវរថយន្តរបស់លោកអ្នក។ ដើម្បីសន្យាទូទាត់សងបំណុលនោះ លោកអ្នកត្រូវតែចុះហត្ថលេខា និង ដាក់ឯកសារកិច្ចសន្យាបញ្ជាក់ឡើងវិញជាមួយនឹងតុលាការ។ កិច្ចសន្យាបញ្ជាក់ឡើងវិញ ស្ថិតក្រោមវិធានច្បាប់ពិសេសៗ និង មានលក្ខណ:ជាការស្ម័គ្រចិត្ត។ វាមិនមានតម្រូវការចាំបាច់តាមច្បាប់ស្តីពីការក្ស័យធន ឬ ច្បាប់ផ្សេងៗទៀតនោះឡើយ។ កិច្ចសន្យាបញ្ជាក់ឡើងវិញ –

- ត្រូវតែមានលក្ខណៈជាការស្ម័គ្រចិត្ត
- មិនត្រូវដាក់បន្ទុកធ្ងន់ធ្ងរខ្លាំងពេកលោកអ្នក ឬ ក្រុមគ្រួសារលោកអ្នកនោះទេ
- ត្រូវតែស្ថិតក្នុងផលប្រយោជន៍ដ៏ខ្ពស់របស់លោកអ្នក និង
- អាចត្រូវបានលុបចោលនៅពេលណាមួយ នៅមុនពេលតុលាការចេញការរំលត់ដល់លោកអ្នក ឬ ក្នុងរយៈពេល 60 ថ្ងៃបន្ទាប់ពីកិច្ចសន្យានេះត្រូវបានដាក់ចូលទៅតុលាការ ដែលទោះជាក្នុងករណីណាក៏ដោយ ក៏ត្រូវផ្តល់ឲ្យលោកអ្នកនូវពេលវេលាច្រើនគ្រប់គ្រាន់បំផុត។

ប្រសិនបើលោកអ្នក ជាបុគ្គលម្នាក់ ហើយលោកអ្នកមិនមានការតំណាងឲ្យដោយមេធាវីម្នាក់ទេនោះ តុលាការត្រូវតែដំណើរការធ្វើសវនាការមួយ ប្រយោជន៍សម្រេចមើលថាតើត្រូវយល់ព្រមឲ្យមានកិច្ចសន្យាបញ្ជាក់ឡើងវិញមួយឬយ៉ាងណានោះ។ កិច្ចសន្យានេះ នឹងមិនចងដោយច្បាប់នោះទេ រហូតដល់តុលាការចេញបញ្ជាក់ការយល់ព្រមលើវា។

ប្រសិនបើលោកអ្នក បញ្ជាក់ឡើងវិញនូវបំណុលមួយ ហើយបន្ទាប់មកខកខានមិនបានទូទាត់ដោះស្រាយសងនោះ លោកអ្នកនៅជំពាក់បំណុលដូចគ្នាដដែល បើទោះណាជាមិនមានការក្ស័យធននោះក៏ដោយ។ បំណុលនេះ នឹងមិនទទួលបានការរំលត់ចោលនោះទេ ហើយម្ចាស់បំណុលអាចចាត់ការណ៍យកមកវិញនូវទ្រព្យសម្បត្តិទាំងឡាយណាដែលវាមានការបង្ខាំងទុក ឬ អ៊ីប៉ូតែក ។ ម្ចាស់បំណុល ក៏អាចមានចំណាត់ការណ៍ផ្លូវច្បាប់បានផងដែរដើម្បីបានមកវិញនូវការសម្រេចសេចក្តីមួយប្រឆាំងនឹងលោកអ្នក។

**ប្រសិនបើលោកអ្នក ចង់ស្វែងយល់បន្ថែមទៀត ឬ មានចម្ងល់ណាមួយអំពីរបៀបដែលច្បាប់ស្តីពីការក្ស័យធនមានឥទ្ធិពលលើលោកអ្នកនោះ លោកអ្នកអាចចាំបាច់ត្រូវមានដំបូន្មានផ្នែកច្បាប់។ អ្នកតំណាងក្នុងករណីរបស់លោកអ្នក មិនមានទំនួលខុសត្រូវចំពោះការផ្តល់ដំបូន្មានផ្នែកច្បាប់ដល់លោកអ្នកឡើយ។**